ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រលេខ ១៥០៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។ លោក/អ្នកក៏អាចទូរស័ព្ទមកកាន់លេខ (+៨៥៥) ១៧ ៥០ ៥០ ៥០ ឬ (+៨៥៥) ២៣ ៧២៦ ៩០១។

ពាក្យសុំរបស់លោក/អ្នកនឹងត្រូវបានពិចារណាដោយ គណៈកម្មាធិការការពារសេរីភាពមូលដ្ឋានដើម្បីពិនិត្យថា តើវាសមស្របនឹងលក្ខខណ្ឌនៃគោលការណ៍របស់ ម.ស.ម.ក ដែរឬទេមុននឹងមានការឆ្លើយតបនឹងសំណើរបស់លោក/អ្នក។

## តើមានអ្វីផ្សេងទៀតដែលខ្ញុំត្រូវដឹងដែរឬទេ?

នៅពេលដែលជំនួយត្រូវបានប្រើប្រាស់ លោក/អ្នកនឹងត្រូវផ្ញើរបាយការណ៍សង្ខេបពន្យល់ពីការប្រើប្រាស់ជំនួយ និងសកម្មភាពរបស់លោក/អ្នក។ អាស្រ័យទៅលើកម្មវត្ថុដើមនៃសំណើ របាយការណ៍នោះអាចតម្រូវឲ្យភ្ជាប់មកជាមួយនូវរូបថត ឬវិក្កយបត្រលើរាល់ចំណាយដែលផ្តល់ដោយ ម.ស.ម.ក។

ម.ស.ម.ក រក្សាសិទ្ធិក្នុងការទាមទារឲ្យលោក/អ្នកសងលើការចំណាយវិញ ប្រសិនបើអង្គការរកឃើញថា ការប្រើប្រាស់ជំនួយមិនសមស្រប ឬពាក់ព័ន្ធនឹងអំពើពុករលួយ។

## ខ្ញុំនៅតែមានសំណួរ តើខ្ញុំអាចសួរនរណាបាន?

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលេខទូរស័ព្ទ និងអ៊ីម៉ែលខាងលើ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ជំនួយថវិកាគម្រោងការពារសេរីភាពមូលដ្ឋាន



## តើលោក/អ្នកត្រូវការជំនួយដែរឬទេ ប្រសិនបើសេរីភាពមូលដ្ឋានរបស់លោក/អ្នក ត្រូវបានរំលោភបំពាន?

## តើអ្វីជាសេរីភាពមូលដ្ឋាន?

ច្បាប់អន្តរជាតិផ្តល់សិទ្ធិឲ្យមនុស្សគ្រប់រូប ក្នុងការរៀបចំប្រមូលផ្តុំ (សេរីភាពក្នុងការបង្កើតសមាគម) រៀបចំការជួបជុំជាសាធារណៈ (សេរីភាពក្នុងការជួបប្រជុំ) និងបញ្ចេញគំនិតជាសាធារណៈ (សេរីភាពខាងការបញ្ចេញមតិ)។ រាជរដ្ឋាភិបាលកម្ពុជាមិនអាចរំលោភបំពានសិទ្ធិទាំងនេះ ឬបង្កឲ្យមានបញ្ហាដល់បុគ្គលណា ម្នាក់ក្នុងការសម្តែងសេរីភាពមូលដ្ឋានរបស់គេបានឡើយ។

## តើគម្រោងការពារសេរីភាពមូលដ្ឋានជាអ្វី? តើគម្រោងនេះគាំទ្រនរណាខ្លះ?

នេះជាគម្រោងមួយរបស់ ម.ស.ម.ក ដើម្បីគាំទ្របុគ្គលទាំងឡាយណាដែលសេរីភាពមូលដ្ឋាន របស់ពួកគេត្រូវបានរឹតត្បិត ឬរំលោភបំពានតាមរយៈការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬតាមរយៈផ្លូវច្បាប់ផ្សេងទៀត។ ករណីនេះអាចរាប់បញ្ចូលទាំងអ្នកការពារសិទ្ធិមនុស្ស (អ.ក.ស.ម) អ្នកកាសែត សហជីព មេធាវី សហគមន៍ សកម្មជនលើបណ្តាញអ៊ីនធឺណែត សកម្មជននយោបាយ បរិស្ថាន អ្នកតវ៉ា។ល។ ប៉ុន្តែក៏ដូចគ្នានឹងក្រុម ឬអង្គការផងដែរ ដរាបណាពួកគេធ្វើសកម្មភាពនានាដោយសន្តិវិធី និងអហិង្សា។

## សិទ្ធិសេរីភាពមូលដ្ឋានរបស់ខ្ញុំត្រូវបានរំលោភបំពាន ឬរឹតត្បិត តើគម្រោងជួយខ្ញុំដោយរបៀបណា?

ប្រភេទនៃជំនួយត្រូវបានផ្តល់ឲ្យអាស្រ័យលើតម្រូវការរបស់បុគ្គលម្នាក់ៗ។ គម្រោងប្រើប្រាស់ថវិកាដែលអាចជួយក្នុងស្ថានភាពផ្សេងគ្នាទាក់ទងនឹងការអនុវត្ត សេរីភាពមូលដ្ឋានរបស់លោក/អ្នកដូចជា៖

### ប្រភេទជំនួយ

#### ផ្នែកច្បាប់

ប្រសិនបើលោក/អ្នកប្រឈមនឹង**ការបំពាន**តាមផ្លូវតុលាការ ឧទាហរណ៍ ប្រសិនបើលោក/អ្នកត្រូវបានកោះហៅតុលាការ ចោទប្រកាន់ ឬឃុំឃាំង គម្រោងអាចផ្តល់មេធាវីជួយផ្នែកច្បាប់ ឬផ្តល់សេវាមេធាវី។

#### សុវត្ថិភាព

ប្រសិនបើ**សុវត្ថិភាព**របស់លោក/អ្នកស្ថិតក្នុងភាពហានិភ័យ ឧទាហរណ៍ លោក/អ្នកទទួលរងនូវការគំរាមកំហែង ឬត្រូវគេតាមដាន គម្រោងអាចផ្តល់ជំនួយសមស្របផ្នែកសុវត្ថិភាព។

#### យុទ្ធនាការ

ប្រសិនបើលោក/អ្នកចង់**រៀបចំសកម្មភាព**ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ឬលើកឡើងអំពីការដាក់កម្រិតលើសេរីភាពបង្កើតសមាគម សេរីភាពក្នុងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ គម្រោងនឹងអាចផ្តល់ការបណ្តុះបណ្តាល និងជំនួយជាក់លាក់ផ្សេងទៀត និងអាចជួយជាជំនួយថវិកាបានផងដែរ។

## តើខ្ញុំអាចដាក់ពាក្យសុំដោយរបៀបណា?

សូមផ្ញើសំណើសុំជំនួយភ្ជាប់មកជាមួយនូវសេចក្តីពន្យល់អំពីស្ថានភាពរបស់លោក/អ្នកមកកាន់ គម្រោងការពារសេរីភាពមូលដ្ឋានតាមរយៈអ៊ីម៉ែល pffp@cchrcambodia.org